USAID
FROM THE AMERICAN PEOPLE

អង្គការអប់រំពិភពលោក
WORLD EDUCATION

# គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា

(IBEC) Project

ខែ មិថុនា ឆ្នាំ ២០១២ លេខ ១០

## ព្រឹត្តិបត្រព័ត៌មានប្រចាំត្រីមាស

### សមិទ្ធិផលក្នុងត្រីមាស

- សិស្សានុសិស្សចំនួន ៦,១០៥នាក់ទទួលបានអាហារូបករណ៍
- សិស្សានុសិស្សចំនួន ៣១,៩៩៤នាក់ ទទួលបានការបង្រៀនអំពីបំណិនជីវិត
- គ្រូថ្មីចំនួន ៧៩នាក់មកពីសាលារៀនថ្មីចំនួន៨ត្រូវបានបំប៉នលើការប្រើប្រាស់ ICT
- ថវិការអំណោយសាលារៀនចំនួន៧០%ត្រូវបានប្រើប្រាស់ក្នុងត្រីមាសនេះ

### ដៃគូគម្រោង IBEC

- គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជាបានទទួលថវិកាពីពលរដ្ឋអាមេរិកតាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ។

គម្រោងត្រូវប្រតិបត្តិ ដោយអង្គការ អប់រំពិភពលោក ដោយមានកិច្ចសហការជាមួយអង្គការខេប និងសហប្រតិបត្តិការជាមួយក្រសួងអប់រំ យុវជន និងកីឡា (MoEYS) ។

- ដៃគូក្នុងស្រុកផ្សេងទៀត មានអង្គការ ៖ WCRD, BSDA, NEP និង EDA
- ដៃគូអន្តរជាតិមានអង្គការ ៖ Equal Access និង AIR

## ការកសាងសមត្ថភាពសម្រេចបាននូវជោគជ័យសំខាន់

### KAPE ជាអង្គការដៃគូទទួលបានវិញ្ញាបនបត្រទទួលស្គាល់ពីគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC)

អង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា (KAPE) ជាអង្គការដៃគូក្នុងស្រុកដ៏សំខាន់មួយក្នុងគម្រោង IBEC ទទួលបានវិញ្ញាបនបត្រទទួលស្គាល់ជាផ្លូវការរបស់ខ្លួនពី CCC នៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ ។ ឥឡូវនេះ KAPE បានក្លាយជាសមាជិកមួយក្នុងចំណោម អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកចំនួន៣០ដែលទទួលបានវិញ្ញាបនបត្រជាផ្លូវការពី CCC ក្នុងប្រទេសកម្ពុជាមកទល់ពេលនេះ ។ KAPE ទទួលបានជោគជ័យចំពោះការអនុវត្តបានតាមគ្រប់បទដ្ឋាននៃអភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈសម្រាប់អង្គការមិនមែនរដ្ឋាភិបាលដែលជាកម្មវិធីមួយផ្តល់វិញ្ញាបនបត្រដោយស្ម័គ្រចិត្តរបស់ CCC បង្កើតឡើងដើម្បីលើកកម្ពស់ស្វ័យនិយតកម្ម ។ CCC ជាអង្គការសមាជិកដែលឲ្យតម្លៃខ្ពស់ដល់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិទាំងអស់ក្នុងប្រទេសកម្ពុជាដែលធ្វើការក្នុងគោលបំណងពង្រឹងគុណភាពអង្គការសង្គមស៊ីវិល ។

តាមរយៈសកម្មភាពកសាងសមត្ថភាពដ៏ធំទូលាយដែលដឹកនាំចាប់តាំងពីឆ្នាំ២០១០មក KAPE បានចាប់ផ្តើមរៀបចំដាក់ពាក្យស្នើសុំនៅដើមឆ្នាំ២០១១ ។ CCC បានពិនិត្យមើលដំណើរការនេះដោយតឹងតែងបំផុត ។ មានបីដំណាក់កាលក្នុងការទទួលបាននូវវិញ្ញាបនបត្រនេះគឺពាក់ព័ន្ធទៅនឹង (i) ការពិនិត្យឯកសារ និងការស៊ើបអង្កេត (ii) ដំណើរការពិនិត្យបញ្ជាក់ឡើងវិញ និង (iii) ការពិនិត្យមើលពីខាងក្រៅ និងការផ្តល់វិញ្ញាបនបត្រ ។ KAPE បានបំពេញនូវដំណាក់កាលចុងក្រោយនៃដំណើរការទទួលស្គាល់នេះក្នុងខែ កញ្ញា ២០១១ និងត្រូវបានជូនដំណឹងអំពីការទទួលស្គាល់ពេញលេញរបស់ខ្លួនដោយ CCC ក្នុងសប្តាហ៍ទី៣នៃខែ កុម្ភៈ ២០១២ ។ ក្នុងនាមជាអង្គការក្នុងស្រុកធំបំផុតដែលធ្វើការលើវិស័យអប់រំក្នុងប្រព័ន្ធការទទួលស្គាល់នាពេលថ្មីៗចំពោះអង្គការ KAPE បានបង្កើតសមត្ថភាពយ៉ាងខ្លាំងដល់មូលដ្ឋានលើការអភិវឌ្ឍក្នុងវិស័យ ។ លទ្ធផលនេះឆ្លើយតបទៅនឹងគោលដៅឆ្ពោះទៅមុខរបស់ USAID លើការជម្រុញសមត្ថភាពអង្គការ NGO មូលដ្ឋានឲ្យមានអភិបាលកិច្ចល្អ ហើយឈានទៅទទួលមូលនិធិដោយផ្ទាល់ពី USAID ។ ការទទួលស្គាល់នេះបានឈានដល់ទីបញ្ចប់នៃការកសាងសមត្ថភាពរយៈពេល៣ឆ្នាំដល់អង្គការ KAPE ដែលឆ្លុះបញ្ចាំងពីភាពជោគជ័យនៃគម្រោង IBEC ។



ថ្ងៃមោទនភាព ៖អ្នកគ្រប់គ្រង និងទីប្រឹក្សាថតរូបបង្ហាញពីវិញ្ញាបនបត្រទទួលស្គាល់ដែលបញ្ជាក់អំពី GPP

ដៃគូទី២គឺ BSDA បានចាប់ផ្តើមដំណើរការដាក់ពាក្យស្នើសុំនេះដែរហើយសង្ឃឹមថានឹងទទួលបានវិញ្ញាបនបត្រនេះនៅចុងឆ្នាំ ២០១២ ៕

## គម្រោង IBEC បានឈានមកដល់ដំណាក់កាលពាក់កណ្តាលផ្លូវ

នៅចុងត្រីមាសទី១០នេះគឺជាដំណាក់កាលពាក់កណ្តាលផ្លូវសម្រាប់រយៈពេល៥ឆ្នាំរបស់គម្រោង IBEC ។ យើងត្រឡប់ទៅមើលការអនុវត្តរបស់គម្រោងរយៈពេលកន្លងមកនេះ គម្រោងបានសម្រេចនូវគោលដៅអនុវត្តសំខាន់ៗរបស់ខ្លួនជាច្រើនរួមមាន (i) បានបញ្ចប់វគ្គបណ្តុះ បណ្តាលលើជំនាញគ្រប់គ្រងសាលារៀន និងភាពជាអ្នកដឹកនាំដល់ថ្នាក់គ្រប់គ្រងសាលារៀនទាំងអស់ (ii) ការបោះពុម្ពសៀវភៅសិក្សាបំណិនជីវិតចំនួន៣០ប្រធានបទ និងបានធ្វើការអនុវត្តសាកល្បង (iii) ការជ្រើសរើសសិស្សអាហារូបករណ៍ជុំទី៣ និង (iv) បញ្ចប់ការរៀបចំសកម្មភាពដើម្បីឲ្យក្រុមប្រឹក្សាឃុំចាប់ផ្តើមតួនាទីរបស់ខ្លួនក្នុងការចាត់ចែងរៀបចំថវិកាសាលារៀន ។

សកម្មភាពបន្តទៀតដែលមានសារៈសំខាន់នោះគឺការបញ្ចប់នៃការអភិវឌ្ឍន៍ដែលមានរយៈពេល៣ឆ្នាំដល់សាលារៀនជាង១០០នៅចុងឆ្នាំនេះ ។ ឥឡូវដំណើរពាក់កណ្តាលផ្លូវរបស់គម្រោងត្រូវបានមកដល់ គម្រោងនឹងចាប់ផ្តើមផ្តោតសំខាន់ឆ្ពោះទៅរកការរួមបញ្ចូលគ្នា និរន្តរភាព និងចែករំលែកនូវករណីសិក្សាសម្រាប់រយៈពេល២ឆ្នាំកន្លះចុងក្រោយនេះ ។ IBEC នឹងធ្វើការជាមួយក្រសួងអប់រំ យុវជន និងកីឡាក្នុងការស្វែងរកមធ្យោបាយដើម្បីឲ្យរដ្ឋាភិបាល ជួយជំរុញក្នុងការអនុវត្តនូវកម្មវិធីសិក្សាបំណិនជីវិតដែលបានបង្កើតកន្លងមក ។ ដំណើរការនេះនឹងចាប់ផ្តើមតាមរយៈការរៀបចំប្រជុំបូកសរុបពាក់កណ្តាលអាណត្តិដែលគ្រោងក្នុងខែឧសភា ២០១២ និងមានសិក្ខាសាលាថ្នាក់ជាតិមួយចំនួនទៀតក្នុងខែសីហា និងកញ្ញា ៕

ព្រឹត្តិបត្រព័ត៌មាននេះអាចផលិតទៅបានដោយមានការឧបត្ថម្ភ ក្រោមជំនួយសប្បុរសធម៌ពីពលរដ្ឋអាមេរិកតាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ។
រាល់ខ្លឹមសារនៅក្នុងព្រឹត្តិបត្រនេះ ជាការទទួលខុសត្រូវរបស់អង្គការអប់រំពិភពលោក និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ USAID ឬរដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ ។
ការិយាល័យអង្គការអប់រំពិភពលោក ៖ ផ្ទះលេខ ២០ ផ្លូវ ២២២ ភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ ៨៥៥-២៣-២១៦ ៨៥៤ E-mail: worldedcam@worlded.org.kh

# សមាសភាគ១៖ ការកសាងសមត្ថភាពមន្ត្រីរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងស្វែងរកការគាំទ្រដើម្បីនិរន្តរភាព

ដូចបានបញ្ជាក់ខាងលើថាការកសាងសមត្ថភាពបានសម្រេចនូវជោគជ័យសំខាន់ក្នុងត្រីមាសនេះដែលទាក់ទងនឹងការទទួលស្គាល់នូវអង្គការសង្គមស៊ីវិល ។ បន្ថែមលើនេះទៀតនាយករងរបស់អង្គការអប់រំពិភពលោកបានមកទស្សនកិច្ចក្នុងប្រទេសកម្ពុជានៅដើមត្រីមាសនេះហើយបានចូលរួមកិច្ចប្រជុំពីរ ឬបីជាមួយដៃគូអភិវឌ្ឍក្នុងស្រុកដើម្បីពិនិត្យឡើងវិញនូវដំណើរការគាំទ្រលើការកសាងសមត្ថភាពពីអង្គការអប់រំពិភពលោក និងទិសដៅទៅអនាគតក្នុងគោលបំណងបង្កើនទំនាក់ទំនងរវាងអង្គការអប់រំពិភពលោក និងដៃគូរបស់ខ្លួន ។ កិច្ចប្រជុំប្រចាំត្រីមាសបានធ្វើឡើងជាមួយដៃគូក្នុងស្រុកទាំងអស់នៅត្រីមាសនេះដើម្បីបញ្ចប់នូវការរៀបចំផែនការស្តង់ដា និងរៀបចំតារាងពេលវេលាសម្រាប់ការចុះតាមដានលទ្ធផលសម្រេចបាននៃគោលបំណងកសាងសមត្ថភាពនេះក្នុងត្រីមាសដែលនៅសល់ ។ ក្រុមពិគ្រោះយោបល់បានបញ្ចប់នូវការផ្លាស់ប្តូរប្រធានថ្មីរបស់ខ្លួន (ឯកឧត្តម សំ សិរីរត្ន) និងបានបន្ថែមនូវសមាជិករបស់ខ្លួនជាមួយនឹងការតែងតាំងថ្មី ។ សមាជិកក្រុមពិគ្រោះយោបល់បានចូលរួមយ៉ាងសកម្មក្នុងការវាយតម្លៃលើការអនុវត្តសាកល្បងកម្មវិធីបំណិនជីវិត និងកាចូលរួមប្រជុំពីគ្រប់សមាជិកដែលប្រព្រឹត្តទៅនៅខែ មីនា ២០១២ ។ កិច្ចប្រជុំរបស់ក្រុមពិគ្រោះយោបល់ថ្នាក់ខេត្តដែលដឹកនាំដោយប្រធានមន្ទីរ ឬអនុប្រធានមន្ទីរប្រព្រឹត្តទៅជាទៀងទាត់អំឡុងពេលត្រីមាសនេះ ចំណុចសំខាន់ៗដែលត្រូវលើកយកមកពិភាក្សាក្នុងកិច្ចប្រជុំនេះរួមមានការបញ្ចូលទុនបដិភាគពីក្រុមប្រឹក្សាឃុំសម្រាប់ឆ្នាំក្រោយ ដោយសាលារៀនជុំទី១បានបញ្ចប់ការអភិវឌ្ឍន៍រយៈពេល៣ឆ្នាំក្នុងឆ្នាំនេះ ។ សមាសភាគនេះក៏បានជ្រើសរើសឃុំចំនួន២ (មួយក្នុងខេត្តក្រចេះ និងមួយទៀតក្នុងខេត្តសៀមរាប) ដើម្បីសាកល្បងដំណើរការផ្តល់ទុនបដិភាគក្នុងគោលបំណងដើម្បីឱ្យគម្រោងឆ្ពោះទៅរកការទទួលបានបទពិសោធន៍ក្នុងការប្តូរទៅប្រើថវិកាឃុំជាមួយទុនបដិភាគពីគម្រោងដើម្បីឱ្យគណៈកម្មការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំមានការទទួលខុសត្រូវកាន់តែប្រសើរឡើងដល់ការជួយគាំទ្រសាលារៀនក្នុងការអនុវត្តឆ្នាំទី៣ សមាសភាគនេះក៏បានសម្រេចចិត្តដើរតួនាទីក្នុងការជួយគាំទ្រផ្នែកបច្ចេកទេសដល់ក្រុមសមាជិកដែលមានមូលដ្ឋាននៅតាមស្រុក និងខេត្តផងដែរ ។ ដំណើរការនេះនឹងធ្វើឱ្យ IBEC ធ្វើការបានយ៉ាងល្អនៅថ្នាក់ឃុំអំឡុងពេលអនុវត្តសកម្មភាពប្រើទុនបដិភាគ និងឆ្លើយតបបានទាន់ពេលវេលានៅពេលណាដែលបញ្ហាកើតមានឡើង ៕

## ការចុះត្រួតពិនិត្យការអនុវត្តគម្រោងរបស់សាលារៀននៅពាក់កណ្តាលអាណត្តិ

ដូចដែល IBEC បានឈានមកដល់ចំណុចពាក់កណ្តាលផ្លូវរបស់ខ្លួន គម្រោងបានដើរតួនាទីយ៉ាងធំក្នុងការចុះត្រួតពិនិត្យការអនុវត្តគម្រោងរបស់សាលារៀនក្នុងពាក់កណ្តាលខែមីនា ។ ចាប់ពីថ្ងៃទី ១២ ដល់ទី១៥ ខែមីនាបុគ្គលិក IBEC ចំនួន១៣ក្រុមបានចុះត្រួតពិនិត្យសាលាបឋមសិក្សាចំនួន៧៤ និង មធ្យមសិក្សាចំនួន១៣១ ។ ការចុះត្រួតពិនិត្យដែលពាក់ព័ន្ធទៅនឹងចំណុចដ៏ច្រើននេះលើសាលារៀនទាំង២០៥នេះគឺដើម្បីវាយតម្លៃក្នុងការទទួលខុសត្រូវលើហិរញ្ញវត្ថុ និងអភិបាលកិច្ច ក៏ដូចជាការវាយតម្លៃទៅលើគុណភាពនៃសកម្មភាពអនុវត្តគម្រោង ។ វាក៏ធ្វើឡើងដើម្បីបង្ហាញអំពីការអនុវត្តគម្រោងទាំងមូលផងដែរ ការកំណត់រកបញ្ហា និងការដោះស្រាយ និងដើម្បីឱ្យអ្នកអនុវត្តគ្រប់ខេត្តទាំងអស់ទទួលខុសត្រូវលើការងាររបស់ខ្លួន ។ បុគ្គលិក IBEC ប្រើឧបករណ៍វាយតម្លៃជាស្តង់ដាមួយក្នុងការធ្វើអង្កេត ។ ការត្រួពិនិត្យនេះបានបង្ហាញថា ១៥% នៃបឋមសិក្សា និង ២៥% នៃមធ្យមសិក្សាមានការកែប្រែនូវស្ថានការរបស់ខ្លួន ។ ដោយការវិនិយោគធនធានដ៏ច្រើនសន្ធឹកសន្ធាប់នៅកម្រិតមធ្យមសិក្សា ការស្វែងរកឃើញនេះបានបង្ហាញថាចំនួនសាលារៀនដែលអនុវត្តបានល្អក្នុងគម្រោងកំពុងឈានទៅរកទិសដៅដ៏ត្រឹមត្រូវមួយ ៕

# សមាសភាគ២ ៖ ការបង្កលទ្ធភាពទទួលបានការអប់រំប្រកបដោយសមធម៌

## កញ្ចប់អំណោយសាលារៀនដែលដឹកនាំដោយអ្នកពាក់ព័ន្ធ

ការិយាល័យ IBEC នៅតាមមូលដ្ឋានបានរាយការណ៍ថាថវិកាអំណោយសាលារៀនចំនួន $២៩០,៨៥០ ដែលបានផ្តល់ឱ្យសាលារៀនក្នុងឆ្នាំនេះត្រូវបានចំណាយសរុបអស់ $១៨០,៥៤៧ ហើយ (ឬ ៦២%) នៅចុងត្រីមាសនេះស្ថិតិរបស់ IBEC បានបង្ហាញថាថវិកាចំនួន ៧០% ត្រូវបានចំណាយ ។ ថវិកាចំណាយជាង ៧៧% ត្រូវបានទូទាត់រួចរាល់ដែលស្របទៅនឹងផែនការរំពឹងទុកសម្រាប់បឋមសិក្សា ចំណែកឯមធ្យមសិក្សា (ដែលមានថវិកាច្រើនជាង) វិញបានទូទាត់រួចរាល់ប្រហែល ៦០% នៃថវិកាចំណាយប៉ុណ្ណោះ ។ ថវិកាអំណោយសាលារៀនគឺជាថវិកាដែលសាលារៀនខ្លួនឯងជាអ្នកធ្វើផែនការចំណាយប្រចាំឆ្នាំ ដើម្បីបង្ហាញអំពីតម្រូវការអប់រំជាក់ស្តែងសម្រាប់សហគមន៍របស់ខ្លួន ។ សាលារៀនដែលខ្វះខាតគ្រូបានធ្វើការជ្រើសរើសគ្រូសហគមន៍ដើម្បីជួយបង្រៀន ។ មានគ្រូសហគមន៍ចំនួន ១២៩ នាក់កំពុងបង្រៀននៅគ្រប់សាលាគោលដៅបឋមសិក្សា នៅក្នុងសហគមន៍ដែលមានជនជាតិភាគតិច កុមារភាគច្រើនមានការយល់ដឹងភាសាខ្មែរតិចតួច ដូច្នេះហើយពួកគេមានការលំបាកក្នុងការមករៀនក្នុងសាលារៀនខ្មែរ ។ ឥឡូវនេះមានគ្រូជំនួយពីរភាសាចំនួន១៨ នាក់នៅតាមសាលាបឋមសិក្សាដែលបានជ្រើសរើស ដែលមានតួនាទីដូចជាអ្នកភ្ជាប់ទំនាក់ទំនងរវាងគ្រូប្រចាំថ្នាក់ និងកុមារដែលមានការលំបាកក្នុងការស្តាប់ ។

ថវិកានេះក៏ត្រូវបានប្រើដើម្បីជួយគាំទ្រសកម្មភាពក្រុមប្រឹក្សាកុមារដែលកំពុងអនុវត្តក្នុងសាលាមធ្យមចំនួន៩៥ និងសាលាបឋមចំនួន ១៧៨ ។ សិស្សដែលមានចំណាប់អារម្មណ៍ចូលរួមក្នុងសកម្មភាពនេះចំនួន ៨,០៣៩នាក់បានដឹកនាំសកម្មភាពដូចជា ការរៀបចំសណ្តាប់ធ្នាប់ការអានក្នុងបណ្ណាល័យ សកម្មភាពបំណិនជីវិត និងរៀបចំសួនក្រៅថ្នាក់ ។ IBEC បានចាត់តាំងបណ្តាញក្រុមប្រឹក្សាកុមារីនៅតាមសាលាបឋមសិក្សា និងមធ្យមសិក្សាដែលមានអត្រាបោះបង់ខ្ពស់នឹងផ្តល់សេវាដល់កុមារីចំនួនជាង ១៤,000នាក់បណ្តាញនេះរួមមានបណ្តាញប្រឹក្សាក្នុងចំណោមមិត្តភ័ក្តិចំនួន ១,៥៣០នាក់ដែលជាអ្នកផ្តល់ការជួយគាំទ្របន្ទាន់ដល់មិត្តរួមថ្នាក់ដែលបានអវត្តមានរយៈពេលយូរ និងអាចឈានទៅរកការបោះបង់ ហើយបានទទួលជោគជ័យក្នុងការលើកទឹកចិត្តដល់កុមារីដែលពួកគេទាំងនោះហៀបនឹងបោះបង់ចោលការសិក្សា ឱ្យពួកគេមករៀនវិញបានចំនួន ១,១៩៦នាក់ ។ សកម្មភាពផ្សេងទៀតដែលគាំទ្រដោយថវិកានេះផងដែររួមមានបណ្តាញកុមារជួយកុមារ ការសម្របសម្រួលព្យាបាលកុមារាដែលមានបញ្ហាពងកោបដោយសេវាកម្មក្នុងស្រុក និងការសម្រេចបាននូវបណ្ណាល័យគម្រូចំនួន១២ ។ ក្រុមសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់ IBEC បានរាយការណ៍ថាពួកគេស្ទើរតែបញ្ចប់ទាំងស្រុងនូវគ្រប់ផែនការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ឆ្នាំនេះ រួមទាំងការជួសជុលថ្នាក់រៀនចំនួន៦០ បណ្ណាល័យចំនួន២៤ បន្ទប់ពិសោធន៍វិទ្យាសាស្ត្រចំនួន៧ និងបន្ទប់កុំព្យូទ័រចំនួន៦ក៏ដូចជាការសាងសង់បង្គន់អនាម័យថ្មីចំនួន៨៥ អាងស្តុកទឹកចំនួន៦៧ រៀបចំប្រព័ន្ធទឹកចំនួន៦៨ និងជីកអណ្តូងបានចំនួន៩ ៕

## កម្មវិធីអាហារូបករណ៍

ការបែងចែកអាហារូបករណ៍ជុំទី២ត្រូវបានធ្វើរួចរាល់ហើយនៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សាក្នុងត្រីមាសនេះ ដែលមានសិស្សងាយរងគ្រោះសរុបចំនួន៦,១០៥នាក់ ។ គម្រោង IBEC បានធ្វើការជាមួយសាលាបឋមសិក្សាចំនួន១៧៧ និងមធ្យមសិក្សាចំនួន៤៣ក្នុងការរៀបចំជំនួយនេះ ហើយត្រូវបានរកឃើញថាអត្រាបោះបង់ចោលការសិក្សានៅកម្រិតបឋមសិក្សាត្រូវបានថយចុះក្នុងត្រីមាសនេះ ចំណែកឯចំនួនសិស្សទទួលផលនៅកម្រិតមធ្យមសិក្សាបានបោះបង់ចោលការសិក្សាតែ២%ប៉ុណ្ណោះដោយហេតុផលដូចជា ស្វែងរកការងារធ្វើ ចំណាកស្រុក និងរៀបការ ។ នៅឯសាលាគរុកោសល្យ និងវិក្រឹត្តការខេត្តដែលគម្រោងបានជួយគាំទ្រដល់គរុសិស្សជួបការលំបាកមកពីសហគមន៍ដើម្បីជួយដោះស្រាយបញ្ហាខ្វះគ្រូវិញមិនមានរបាយការណាដែលបង្ហាញពីការបោះបង់នោះទេ ។ ប្រាក់ឧបត្ថម្ភប្រចាំខែចំនួន $២០សម្រាប់គរុសិស្សនីមួយៗបានបើកជូនទាន់ពេលវេលា ។ IBEC បានធ្វើការយ៉ាងជិតស្និទ្ធជាមួយមន្ទីរអប់រំខេត្តដើម្បីធ្វើការសម្ភាសន៍ និងកំណត់ជ្រើសរើសបេក្ខជនអាហារូបករណ៍ដែលពួកគេពិតជាមកពីសហគមន៍ដែលក្រសួងបានរៀបចំឡើងជាអាទិភាពចម្បងដើម្បីបម្រើឱ្យការខ្វះខាតគ្រូ ៕

# ការអប់រំផ្សព្វផ្សាយតាមរយៈវិទ្យុ និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ



ការចូលរួមពីសិស្សមានកម្រិតខ្ពស់ ៖ សិស្សក្នុងក្រុមអ្នកស្តាប់ផ្តល់ព័ត៌មានត្រឡប់

ដៃគូរបស់ IBEC អង្គការ Equal Access បានកំពុងអនុវត្តគ្រប់ផែនការសកម្មភាពទាំងអស់របស់ខ្លួន ក្នុងការជួយ IBEC ដើម្បីផ្សព្វផ្សាយព័ត៌មាន និងដំណឹងស្តីអំពីអន្តរាគមន៍របស់គម្រោង ។ EA បានរៀបចំកម្មវិធីបំណិនជីវិតតាមវិទ្យុដែលហៅថាកម្មវិធី *យើងអាចធ្វើបាន* និងសកម្មភាពចូលរួមពីសហគមន៍ សកម្មភាពសំខាន់ៗមួយចំនួនត្រូវបានបញ្ចប់ក្នុងត្រីមាសនេះរួមមាន ការបង្កើតមាតិការសម្រាប់ផលិតកម្មវិធីវិទ្យុ និងផ្សព្វផ្សាយ ការផ្តល់នូវទិន្នន័យតាមដានសម្រាប់ក្រុមអ្នកស្តាប់ និងក្រុមសិស្សសន្ទនា ។ នៅដើមត្រីមាសនេះ EA បានរៀបចំដំណើរការផលិតនូវកម្មវិធីបំណិនជីវិតតាមវិទ្យុថ្មីមួយ ជាមួយនឹងការពិនិត្យឡើងវិញនូវព័ត៌មានត្រឡប់ដែលបានមកពីទស្សនិកជនតាមរយៈកម្មវិធីសំនួរចម្លើយ ជាពិសេសគឺក្រុមអ្នកស្តាប់ដែលពួកគេបានចូលរួមស្តាប់ចាប់តាំងពីកម្មវិធីធ្វើការផ្សាយជាលើកដំបូងមកម្លេះ ។

EA បានបញ្ចប់ផែនការដើម្បីប្តូរទៅជាអ្នកប្រតិបត្តិការក្នុងស្រុករបស់ខ្លួន ហើយបានបញ្ចប់នូវការផ្ទេរគ្រប់សកម្មភាពរបស់ខ្លួនទៅឲ្យអង្គការថ្មីមួយដែលមានឈ្មោះថា Media One ។ Media One នឹងទទួលកិច្ចសន្យារយៈពេលខ្លីពីអង្គការអប់រំពិភពលោកនៅត្រីមាសបន្ទាប់ដោយមានការយល់ព្រមពី USAID ដើម្បីបន្តការពិនិត្យតាមដានសកម្មភាពរហូតដល់ចប់ឆ្នាំសិក្សាថ្មី ៕

## *ការផ្សព្វផ្សាយតាមរយៈសៀវភៅតុក្កតា*

ផ្នែកមួយនៃសកម្មភាពផ្សព្វផ្សាយរបស់ IBEC EA បានផលិតសៀវភៅភាគតុក្កតា ដែលគ្រប់សៀវភៅទាំងអស់បានបង្ហាញពីប្រធានបទលើកឡើងក្នុងកម្មវិធីវិទ្យុ *យើងអាចធ្វើបាន* ដែលបានបញ្ចូលសារសំខាន់ៗពីរឿងខ្លីទាំងនោះផងដែរ ។ សៀវភៅក៏បានបញ្ចូលនូវលំហាត់ដែលមានភាពទាក់ទាញដែលធ្វើឡើងដើម្បីឲ្យមានការចូលរួម ការកំសាន្ត និងអប់រំយុវជនអំពីបំណិនជីវិតដែលបានពិភាក្សានៅក្នុងកម្មវិធីវិទ្យុ ។ ក្នុងត្រីមាសនេះ សៀវភៅតុក្កតាចំនួន២បានបញ្ចប់រួចរាល់ ដែលនិយាយអំពីប្រធានបទផែនការអាជីព និងបំណិនជីវិត ។ សៀវភៅសរុបជាង២000ក្បាលបានបែងចែកដល់សាលារៀនចំនួន១០១ ក្នុងខេត្តកំពង់ចាម សៀមរាប និងក្រចេះ ៕




សៀវភៅតុក្កតា ៖ ទីប្រឹក្សាអាជីព (ឆ្វេង) បំណិនជីវិតធ្វើឲ្យ Coco និង Yoyo ទទួលបានប្រាក់ចំណូល (ស្តាំ)



អ្នកទទួលបានជ័យជំនះក្នុងកម្មវិធីក្រុមសិស្សយកព័ត៌មានមានភាពក្លាហានក្នុងការបង្ហាញពីភាពជោគជ័យរបស់ខ្លួន

សិស្សទី៣ដែលទទួលបានជ័យជំនះក្នុងកម្មវិធីប្រគួតប្រជែងអ្នកយកព័ត៌មានបានបង្ហាញអំពីបច្ចេកទេសផ្ទាល់ខ្លួន ។ គេត្រូវបានតម្រូវឲ្យជ្រើសរើសប្រធានបទ និងធ្វើការសហការដើម្បីផលិតនូវព័ត៌មានដោយខ្លួនឯង ។ គេផលិតដោយខ្លួនឯង និងធ្វើការសម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធមានដូចជា នាយកសាលា គ្រូបង្រៀន មិត្តរួមថ្នាក់ និងសមាជិកក្រុមអ្នកស្តាប់ អ្នកទទួលបានជ័យជំនះជាសិស្សមធ្យមសិក្សាមកពីវិទ្យាល័យ ហស ប៊ុីស២ ៕

# សមាសភាគ៣ ៖ ការកែលម្អការគ្រប់គ្រងសាលារៀន និងការចូលរួមពីសហគមន៍

សកម្មភាពក្នុងត្រីមាសនេះគឺការបណ្តុះបណ្តាលលើកទី៤ និងបញ្ចប់នូវសិក្ខាសាលាបំប៉នលើការគ្រប់គ្រងសាលារៀន និងភាពជាអ្នកដឹកនាំដែលធ្វើឡើងក្នុងខេត្តទាំង៣ ។ សិក្ខាសាលាបានចូលរួមដោយបុគ្គលិករដ្ឋបាលសាលារៀនមកពីសាលារៀនគោលដៅរបស់ IBEC ដែលនាំមកនូវការពិគ្រោះយោបល់ទៅលើការដោះស្រាយបញ្ហាដោយមានហេតុផលដើម្បីធ្វើឲ្យប្រសើរឡើងនូវការគ្រប់គ្រង និងការត្រួពិនិត្យទៅលើការវិនិយោគផ្សេងៗដែលបានធ្វើឡើងក្នុងសាលារៀនរបស់ពួកគេ ។ សិក្ខាសាលាក៏បានពិភាក្សាផងដែរទៅលើប្រធានបទដូចជា ភាពចាំបាច់នៃទស្សនវិស័យរបស់សាលា របៀបភ្ជាប់ទំនាក់ទំនងជាមួយសហគមន៍ និងការសាកល្បងដោះស្រាយបញ្ហាដោយវិភាគ សិក្ខាសាលាដែលធ្វើឡើក្នុងត្រីមាសនេះត្រូវបានចូលរួមដោយបុគ្គលិករដ្ឋបាលសាលារៀនចំនួន៣៤២នាក់ ។ ដើម្បីឲ្យមាននិរន្តរភាពខ្ពស់សម្រាប់សកម្មភាពកសាងសមត្ថភាពនេះ សិក្ខាសាលាបានដឹកនាំដោយគ្រូឧទ្ទេសចំនួន៣១នាក់មកពីក្រសួងអប់រំដែលធ្វើការជ្រើសរើសចេញពីមន្ទីរអប់រំខេត្ត និងការិយាល័យអប់រំស្រុក ។ គ្រូឧទ្ទេសទាំងអស់បានចូលរួមវគ្គបណ្តុះបណ្តាលគ្រូឧទ្ទេសចំនួន៣ថ្ងៃក្នុងខេត្តសៀមរាបក្នុងគោលបំណងដើម្បីរៀបចំសម្រាប់វគ្គសិក្ខាសាលាធំ ។ ការបណ្តុះបណ្តាលគ្រូឧទ្ទេសរួមមានការទស្សនកិច្ចទៅកាន់សាលារៀនគម្រូក្នុងខេត្តសៀមរាប ដើម្បីទស្សនាផ្ទាល់អំពីការអនុវត្តលើការគ្រប់គ្រងជាក់ស្តែង អ្នកចូលរួមក្នុងសិក្ខាសាលាទាំង៩វគ្គនឹងឈានទៅដល់ការផ្តល់វិញ្ញាបនបត្រ ផ្អែកទៅលើការពិនិត្យឡើងវិញអំពីការចូលរួមក្នុងវគ្គសិក្ខាសាលា និងបញ្ចប់ការងារដែលបានកំណត់នៅពេលដែលពួកគេត្រឡប់ទៅសាលារៀនរបស់ខ្លួនវិញ ។



គ្រូឧទ្ទេស និង DPO ធ្វើការជាក្រុមតូចដើម្បីរៀបចំផែនការសកម្មភាពក្នុងសិក្ខាសាលាការគ្រប់គ្រងសាលារៀន និងភាពជាអ្នកដឹកនាំលើកទី៤ ក្នុងខេត្តសៀមរាប

IBEC កំពុងបន្តធ្វើការបំប៉នសមត្ថភាពដល់គណកម្មការទ្រទ្រង់សាលា (SSCs) ដើម្បីបង្កើនការចូលរួមរបស់ពួកគាត់ក្នុងវិស័យអប់រំ ។ ការលើកឡើងនូវការងារនេះគឺដើម្បីជួយ SSCs ឲ្យមានការគិតកាន់តែប្រសើរលើការលើកកម្ពស់ការអប់រំ និងគុណភាពអប់រំក្នុងសាលារៀនរបស់ពួកគាត់ ។ បុគ្គលិកនៅតាមបណ្តាខេត្តបានធ្វើសិក្ខាសាលាឆ្លុះបញ្ចាំងជាមួយ SSCs ចំនួន២៨៤នាក់ ក្នុងខែកុម្ភៈ និងធ្វើការប្រមូលទិន្នន័យវាយតម្លៃពីផលប៉ះពាល់របស់គណកម្មការ ។ SSCs មានសមាជិកដែលមកពីសហគមន៍ក្នុងតំបន់ដែលធ្វើការជាមួយគ្នាដើម្បីគាំទ្រ និងជួយរៀបចំផែនការសកម្មភាពជាក់ស្តែងរបស់សាលារៀន ដូចជាការបែងចែកអាហារូបករណ៍ និងការបង្រៀនកម្មវិធីបំណិនជីវិត ។ IBEC ក៏បានធ្វើសិក្ខាសាលាតម្រង់ទិសដល់ SSCs អំពី “ការពង្រឹងអំណាន” ក្នុងការជួយគាំទ្រការអានថ្នាក់ដំបូង ។ ដោយ USAID ថ្មីៗនេះបានផ្សព្វផ្សាយអំពីយុទ្ធសាស្ត្រអប់រំ SSCs ចំនួន៨៨នាក់បានចូលរួមសិក្ខាសាលាដែលពិភាក្សាអំពីវិធីសាស្ត្របង្កើនការចូលរួមរបស់អាណាព្យាបាលដើម្បីជួយគាំទ្រកូនៗរបស់ពួកគេក្នុងការអាន ការតាមដានថ្នាក់បំប៉នសិស្សរៀនយឺត និងជួយសាលារៀនក្នុងការជួយគាំទ្រសកម្មភាពកុមារជួយកុមារ ៕

# សមាសភាគ៤៖ ការកែលម្អបរិបទទំនាក់ទំនងអប់រំ

## ក្របខណ្ឌបំណិនជីវិត

ការអនុវត្តកម្មវិធីបំណិនជីវិតសាកល្បងបានឈានមកដល់ដំណាក់កាលចុងបញ្ចប់ក្នុងត្រីមាសនេះ ។ ជារួមមានសាលាមធ្យមសិក្សាចំនួន៩៧ដែលអនុវត្តការអប់រំបំណិនជីវិត ។ ការិយាល័យ IBEC នៅតាមមូលដ្ឋានបានរាយការណ៍ថាមានសិស្សមធ្យមសិក្សាចំនួនប្រហែល ៣១,៩៩៤នាក់ (ស្រីចំនួន ១៦,៣៦២នាក់) បានចូលរួមក្នុងការអប់រំបំណិនជីវិតលើប្រធានបទផ្សេងៗគ្នាក្នុងខេត្តគោលដៅទាំង ៣ ។ នៅថ្នាក់បឋមសិក្សា IBEC កំពុងបន្តសកម្មភាពកម្មវិធីបំណិនជីវិតដើម្បីទប់ស្កាត់ការបោះបង់ និងដើម្បីឲ្យពួកគេឆ្លងទៅមធ្យមសិក្សា ។ ពេលបច្ចុប្បន្នមានសិស្សបឋមសិក្សាចំនួនប្រហែល៨,៤៤៩នាក់បានចូលរួមក្នុងការអប់រំបំណិនជីវិត ជាពិសេសនៅថ្នាក់ទី៥ និងទី៦ ដែលជាកម្រិតអាចនឹងមានការបោះបង់ចោលការសិក្សាខ្ពស់ ។ អន្តរាគមន៍ចម្បងក្នុងត្រីមាសនេះគឺការចាប់ផ្ដើមនូវប្រធានបទថ្មីស្ដីពីការប្រឹក្សាអាជីពដល់សិស្ស ។ នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ (VOD) និង IBEC បានធ្វើការយ៉ាងជិតស្និទ្ធដើម្បីជួយសាលារៀនបង្កើតនូវប្រព័ន្ធប្រឹក្សាអាជីពក្នុងសាលារៀនដែលបានជ្រើសរើសចំនួន ២២ ក្នុងការផ្សារភ្ជាប់ជាមួយប្រធានបទបំណិនជីវិតមួយចំនួនដូចជា "ពិភពការងារ" ។ ការវាយតម្លៃទៅលើការសាកល្បងដែលបានធ្វើឡើងក្នុងត្រីមាសនេះ បង្ហាញថាមានការសហការជាមួយក្រសួងអប់រំយ៉ាងខ្លាំងបំផុត ក៏ដូចជាមានការចូលរួមយ៉ាងច្រើនពីដៃគូរដ្ឋាភិបាលតាមរយៈនាយកដ្ឋានផ្សេងៗ ។ ការវាយតម្លៃនេះក៏បានផ្ដោតផងដែរទៅលើទ្រង់ទ្រាយថ្មីនៃកម្មវិធីសិក្សាបំណិនជីវិត យុទ្ធសាស្ត្រនៃការអនុវត្ត និងវិធីសាស្ត្របង្រៀន ។ ដោយភាពជាក់ស្ដែងក្រសួងអប់រំអាចនឹងធ្វើការពិនិត្យឡើងវិញនូវគោលនយោបាយបំណិនជីវិតរបស់ខ្លួន ការវាយតម្លៃទៅលើការអនុវត្តសាកល្បងកម្មវិធីបំណិនជីវិតរបស់ IBEC ប្រហែលជាមិនអាចបញ្ចប់ទាន់ពេល ៕




អ្វីដែលជាលើកដំបូងមួយទៀត៖ សៀវភៅទីប្រឹក្សាអាជីពសម្រាប់សាលារៀនដែលបង្កើតជាលើកដំបូងសម្រាប់ប្រទេសកម្ពុជា ។ VOD គ្រោងនឹងកែសម្រួលមេរៀននេះ ហើយបោះពុម្ពដោយដាក់និមិត្តសញ្ញារបស់ក្រសួងអប់រំ

## ករណីសិក្សា ៖ សិស្សមានការចូលរួមក្នុងកម្មវិធីបំណិនជីវិត



រតនាមានអាយុ ១៥ឆ្នាំ នាងរស់នៅក្នុងភូមិតូចមួយក្នុងខេត្តកំពង់ចាមជាមួយឪពុកម្ដាយ និងបងប្អូន៣នាក់ផ្សេងទៀត ។ នាងរៀនថ្នាក់ទី៧ និងជាអ្នកដឹកនាំក្រុមប្រឹក្សាកុមារ ការរៀបចំរចនាសម្ព័ន្ធរបស់សាលារៀនបែបនេះ គឺមានការចូលរួមយ៉ាងច្រើនក្នុងការអប់រំបំណិនជីវិត ។ ជាមួយនឹងការប្រឹក្សាដែលមានសមាជិកចំនួន២៣នាក់របស់នាង នាងបានចូលរួមក្នុងការសម្រេចចិត្តជ្រើសរើសប្រធានបទបំណិនជីវិតណាដែលមានការទាក់ទងទៅនឹងសាលារៀនរបស់នាង ។ ពួកគេបានជ្រើសរើសប្រធានបទស្ដីអំពី "ខ្ញុំ និងអនាគតរបស់ខ្ញុំ" "បញ្ហាបរិស្ថាន" "ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន" " ពិភពការងារ" និង "ចំណាកស្រុកដោយសុវត្ថិភាព" ។



រតនាយល់ច្បាស់អំពីកម្មវិធីបំណិនជីវិត និងមានគំនិតអនុវត្តច្រើន ។ នាងជឿជាក់ថាមុខវិជ្ជាអក្សរសាស្ត្រខ្មែរ និងគណិតវិទ្យានឹងអាចធ្វើឲ្យនាងក្លាយជាគ្រូបង្រៀនបាននៅថ្ងៃអនាគត ប៉ុន្តែនាងនិយាយថា "ប្រសិនបើខ្ញុំរៀនពីរបៀបធ្វើការក្នុងសួនជីវៈ ខ្ញុំអាចបណ្ដុះកូនឈើ និងអាចលក់វានៅទីផ្សារបាន" ឆ្នាំក្រោយរតនាចង់រៀនអំពី "ចំណាកស្រុកដោយសុវត្ថិភាព" ព្រោះនាងគិតថាវាមានសារៈសំខាន់ក្នុងការផ្ដល់ព័ត៌មានផ្លូវច្បាប់អំពីការផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត ។

រតនាត្រូវបានជ្រើសរើសដោយមិត្តរួមថ្នាក់របស់នាងដើម្បីដឹកនាំក្នុងក្រុមប្រឹក្សាកុមារ ហើយនាងបានពន្យល់ថា ពួកគេមានការប្រជុំ៣ដងក្នុងឆ្នាំនេះជាមួយសមាជិកក្រុមទាំងអស់ នាយកសាលា និងគ្រូបង្រៀនបំណិនជីវិតចូលរួមក្នុងការប្រជុំណាដែលមានករណីពិសេសប៉ុណ្ណោះ ។ នាងចូលរួមក្នុងគណៈកម្មការត្រួតពិនិត្យ និងគណៈកម្មការបំណិនជីវិត ។ គោលបំណង IBEC គឺចង់ឲ្យក្រុមប្រឹក្សាកុមារចូលរួមក្នុងសកម្មភាពអប់រំទាំងអស់ វាមានន័យថា ការរៀបចំមេរៀន ការថែរក្សាសម្ភារៈ និងតាមដានដល់ការងារផ្ទះ ឬសកម្មភាពផ្សេងៗរបស់សហគមន៍ ។ ការងារ និងភាពទទួលខុសត្រូវរបស់សិស្ស បានបង្កើតឲ្យមានការតាំងចិត្ត និងភាពជាម្ចាស់ ដែលមានន័យថាជាការផ្សារភ្ជាប់ក្នុងបទពិសោធន៍សិក្សា ៕

## ការបណ្ដុះបណ្ដាលគ្រូ

សាលារៀននៅតំបន់ដាច់ស្រយាលតែងតែជួបប្រទះនូវបញ្ហាកង្វះគ្រូ និងមិនមានជំនួយចំពោះតម្រូវការផ្សេងៗរបស់សិស្ស ។ ដើម្បីឆ្លើយតបនឹងតម្រូវការនេះ IBEC បានបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការកសាងសមត្ថភាពផ្ដល់ការបំប៉នរំឭកឡើងវិញដល់គ្រូសហគមន៍ចំនួន១១៣នាក់ដែលធ្វើការជ្រើសរើសដើម្បីបំពេញតម្រូវការរបស់សាលារៀនទាំង៣ខេត្ត ។ ការបំប៉នរំឭកឡើងវិញនេះផ្ដោតលើការស្វែងរកបញ្ហា និងបទពិសោធន៍ជោគជ័យរបស់គ្រូសហគមន៍ក៏ដូចជាការបង្កើនចំណេះដឹង និងជំនាញរបស់ពួកគាត់លើប្រធានបទដូចជាជំនាញចោទសួរ ការគ្រប់គ្រងថ្នាក់រៀន និងការបង្កើតល្បែងសិក្សា ។ ក្រុមការងារ IBEC បានផ្ដល់វគ្គបំប៉នដល់គ្រូបំប៉នសិស្សរៀនយឺតថ្មីចំនួន១២៨នាក់ (ស្រី៣៥នាក់) នៅតាមសាលាបឋមសិក្សា និងមធ្យមសិក្សាដែលចាប់ផ្ដើមធ្វើក្នុងខែកុម្ភៈ ។ ថ្នាក់បំប៉នសិស្សរៀនយឺតមានសិស្សជាក្រុមចំនួន២០នាក់ ឬតិចជាងនេះហើយសិស្សទាំង៣៦ក្រុមនោះនឹងចាប់ផ្ដើមក្នុងខែកុម្ភៈ ឆ្នាំ២០១២ ។ យោងតាមរបាយការណ៍របស់ការិយាល័យ IBEC នៅតាមមូលដ្ឋានមានកុមារចំនួន៥,៣២៦ដែលត្រូវការ ការសិក្សាពិសេសត្រូវបានទទួលការគាំទ្រនេះ(ស្រី២,៦៨៧) ។ បុគ្គលិក IBEC ក៏បានធ្វើការជាមួយសាលារៀនដើម្បីផ្ដល់សកម្មភាពពិសេសមួយចំនួនដូចជា ក្លឹបអាន ការបង្រៀនតាមរយៈកម្មវិធីកុមារជួយកុមារ ដែលជាការលើកកម្ពស់ការអាន និងជំនាញសរសេររបស់កុមារ ។ ផ្នែកខ្លះនៃផែនការនេះគឺដើម្បីបញ្ចូលនូវជំនាញមូលដ្ឋានដែលនឹងធ្វើការប្រឡងនៅចុងឆ្នាំសិក្សាដោយប្រើទម្រង់វាយតម្លៃការអានថ្នាក់ដំបូងរបស់ក្រសួងអប់រំ ដែលបានបង្កើតឡើងសម្រាប់ធ្វើការសាកល្បងសៀវភៅអានថ្នាក់ទី១ ។ ក្នុងត្រីមាសនេះក្រុមការងារ IBEC ដឹកនាំការធ្វើអង្កេតដ៏សំខាន់មួយដើម្បីស្វែងរកនូវប្រសិទ្ធភាពនៃការបំប៉នគ្រូ ។ តាមការរំពឹងទុកនៃការធ្វើអង្កេតទៅលើគ្រូកុមារមេត្រីនៅបឋមសិក្សា និងមធ្យមសិក្សាបានរកឃើញថាមានគ្រូបឋមសិក្សាចំនួន ៨៤% និងគ្រូមធ្យមសិក្សាចំនួន៨៣% គ្រូភាគច្រើនដែលបានអង្កេតបានអនុវត្តតាមស្តង់ដាអាចទទួលយកបាន ៕

## ការគាំទ្រផ្នែកបច្ចេកវិទ្យាព័ត៌មាន



បន្ទប់កុំព្យូទ័រចំនួន៨ដែលត្រូវកសាងឡើងក្នុងឆ្នាំនេះ បានបញ្ចប់ដោយជោគជ័យក្នុងខេត្តកំពង់ចាម និង សៀមរាប ។ បន្ទប់កុំព្យូទ័រចំនួន២ក្នុងចំណោម៨នេះត្រូវបានកសាងឡើងដោយទទួលបរិភាគពីមូលនិធិ Oaktree ។ គម្រោងបានតំឡើងកុំព្យូទ័រចំនួន១៤៨គ្រឿងដែលមាន២៣បន្ទប់ក្នុងពេលបច្ចុប្បន្ន រួមទាំងការបង្កើតបន្ទប់កុំព្យូទ័រថ្មីៗនេះ IBEC បានធ្វើការបំប៉នគ្រូសរុប៧៩នាក់ដែលនឹងត្រូវបានចាត់តាំងជាគ្រូកុំព្យូទ័រក្នុងសាលារៀនរបស់ខ្លួន ។ បន្ថែមទៅលើគ្រូកុំព្យូទ័រ ក្នុងត្រីមាសនេះក្រុមការងារបានធ្វើការបំប៉នគ្រូចំនួន៧៨នាក់ដែលបង្រៀនមុខវិជ្ជាផ្សេងៗក្នុងការប្រើប្រាស់កុំព្យូទ័រដើម្បីជួយពួកគាត់ក្នុងការផ្សារភ្ជាប់ ICT ទៅក្នុងការបង្រៀន និងរៀន ។ មកទល់ពេលនេះមានគ្រូដែលមកពីមុខវិជ្ជាផ្សេងៗ បានចូលរួមក្នុងការបំប៉នលើការប្រើប្រាស់កុំព្យូទ័រចំនួន ៣៥១នាក់ ។

IBEC កំពុងបន្តលើកកម្ពស់គាំទ្រវិធីសាស្ត្រការងារគម្រោងដើម្បីផ្សារភ្ជាប់ការសិក្សាក្នុងថ្នាក់ និង ICT ។ ជាលទ្ធផលក្នុងកិច្ចខិតខំប្រឹងប្រែងនេះចំនួនសិស្សដ៏ច្រើនកំពុងធ្វើការស្រាវជ្រាវគម្រោងក្នុងសាលារៀនរបស់ពួកគេដោយប្រើវិធីសាស្ត្រនេះ និងត្រូវធ្វើបទបង្ហាញនូវលទ្ធផលស្រាវជ្រាវរបស់ពួកគេក្នុងព្រឹត្តិការណ៍ដែលនឹងធ្វើឡើងនៅតាមខេត្តនីមួយៗនៅចុងខែឧសភា ឆ្នាំ២០១២ ។ IBEC ក៏កំពុងពង្រីកចំនួនសាលារៀនដែលផលិតនូវព្រឹត្តិបត្រសាលារៀនរហូតដល់១២សាលាដែលជាចំនួនលើស៤ដងពីឆ្នាំមុន ។ បុគ្គលិកគម្រោងបានធ្វើការបំប៉ន គ្រូចំនួន២២នាក់ក្នុងការប្រើកម្មវិធី Ms. Publisher ដើម្បីធ្វើការផលិតព្រឹត្តិបត្រ ក៏ដូចជាការបង្កើតគំនូព្រាង គោលការណ៍អ្នកសារព័ត៌មាន និងផ្សារភ្ជាប់ទៅនឹងការចូលរួមពីសង្គមស៊ីវិល ។ សាលារៀននីមួយៗទទួលបានម៉ាស៊ីនកាមេរ៉ាឌីជីថលដើម្បីសម្រួលក្នុងការបញ្ចូលរូបភាពទៅក្នុងការបោះពុម្ពព្រឹត្តិបត្រក៏ដូចជាការផ្ដល់ម៉ាស៊ីនបោះពុម្ព (Printer) ប្រភេទក្រដាស A3 ដើម្បីបោះពុម្ពព្រឹត្តិបត្រផងដែរ ៕